**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧០២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់សមមូលឋានន្តរសក្តិមន្ត្រីពន្ធនាគារ ជាមួយនឹងឋានន្តរសក្តិមន្ត្រីរាជការស៊ីវិល និងឋានន្តរសក្តិមន្ត្រីនគរបាលជាតិ និងការធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម លេខ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៩និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.—**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីសមមូលឋានន្តរសក្តិមន្ត្រីពន្ធនាគារជាមួយឋានន្តរសក្តិមន្ត្រីរាជការស៊ីវិល និងឋានន្តរសក្តិមន្ត្រីនគរបាលជាតិ និងកំណត់គោលការណ៍សមាហរណកម្មផ្ទេរបញ្ចូលមន្ត្រីរាជការទៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ស្របតាមលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ។

**មាត្រា២.—**

អនុក្រឹត្យនេះមានគោលដៅ :

- កំណត់សមមូលឋានន្តរសក្តិមន្ត្រីពន្ធនាគារ ឋានន្តរសក្តិមន្ត្រីរាជការស៊ីវិល និងឋានន្តរសក្តិមន្ត្រីនគរបាលជាតិ ដើម្បីសម្រួលដល់ការរៀបចំឋានន្តរសក្តិនៅពេលមានការផ្ទេរពីក្របខ័ណ្ឌមួយទៅក្របខ័ណ្ឌមួយទៀត
- កំណត់គោលការណ៍សមាហរណកម្ម ដើម្បីផ្ទេរបញ្ចូលមន្ត្រីរាជការទាំងឡាយដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដនៅក្នុងរចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធនាគារ។

**មាត្រា៣.—**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការទាំងឡាយដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដនៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ឬក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ឬក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ចំណុះក្រសួងមហាផ្ទៃ។

## ជំពូកទី២
## ការកំណត់អំពីសមមូលឋានន្តរសក្តិ

**មាត្រា៤.—**

ការធ្វើសមមូលឋានន្តរសក្តិ រវាងឋានន្តរសក្តិមន្ត្រីពន្ធនាគារជាមួយនឹងឋានន្តរសក្តិមន្ត្រីរាជការស៊ីវិល និងឋានន្តរសក្តិមន្ត្រីនគរបាលជាតិ ត្រូវបានកំណត់ដូចខាងក្រោម:

**ក. ឋានន្តរសក្តិ ថ្នាក់ឧត្តមអគ្គានុរក្សពន្ធនាគារ**

១- ឋានន្តរសក្តិ ឧត្តមអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ១ សមមូលជាមួយនឹងឋានន្តរសក្តិ :
- ឧត្តមសេនីយ៍ឯកនៃមន្ត្រីនគរបាលជាតិ
- ឧត្តមមន្ត្រី ថ្នាក់លេខ ៣ ដល់ថ្នាក់លេខ១នៃមន្ត្រីរាជការស៊ីវិល

២- ឋានន្តរសក្តិ ឧត្តមអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ២ សមមូលជាមួយនឹងឋានន្តរសក្តិ :
- ឧត្តមសេនីយ៍ទោនៃមន្ត្រីនគរបាលជាតិ
- ឧត្តមមន្ត្រី ថ្នាក់លេខ ៦ ដល់ថ្នាក់លេខ៤នៃមន្ត្រីរាជការស៊ីវិល
- វរមន្ត្រីនៃមន្ត្រីរាជការស៊ីវិល

៣- ឋានន្តរសក្តិ ឧត្តមអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ៣ សមមូលជាមួយនិងឋានន្តរសក្តិ :
- ឧត្តមសេនីយ៍ត្រីនៃមន្ត្រីនគរបាលជាតិ
- អនុមន្ត្រី ថ្នាក់លេខ ១២ ដល់ថ្នាក់លេខ១នៃមន្ត្រីរាជការស៊ីវិល

**ខ. ឋានន្តរសក្តិ ថ្នាក់វរអគ្គានុរក្សពន្ធនាគារ**

១- ឋានន្តរសក្តិវរអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ១ សមមូលជាមួយនឹងឋានន្តរសក្តិ :
- វរសេនីយ៍ឯកនៃមន្ត្រីនគរបាលជាតិ
- អនុមន្ត្រីថ្នាក់លេខ ១៤ដល់ថ្នាក់លេខ ១៣នៃមន្ត្រីរាជការស៊ីវិល

២- ឋានន្តរសក្តិ វរអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ២ សមមូលជាមួយនឹងឋានន្តរសក្តិ :
- វរសេនីយ៍ទោនៃមន្ត្រីនគរបាលជាតិ
- នាយក្រមការនៃមន្ត្រីរាជការស៊ីវិល

៣- ឋានន្តរសក្តិវរអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ៣ សមមូលជាមួយនឹង :
- វរសេនីយ៍ត្រីនៃមន្ត្រីនគរបាលជាតិ
- ក្រមការដើមខ្សែនៃមន្ត្រីរាជការស៊ីវិល
- ក្រមការនៃមន្ត្រីរាជការស៊ីវិល

**គ. ឋានន្តរសក្តិ ថ្នាក់អគ្គានុរក្សពន្ធនាគារ**

១- ឋានន្តរសក្តិ អគ្គានុរក្សពន្ធនាគារថ្នាក់លេខ ១ សមមូលជាមួយនឹងឋានន្តរសក្តិ :
- អនុសេនីយ៍ឯកនៃមន្ត្រីនគរបាលជាតិ
- នាយលេខាធិការរដ្ឋបាលថ្នាក់លេខ ៤ ដល់ថ្នាក់លេខ ១ នៃមន្ត្រីរាជការស៊ីវិល

២- ឋានន្តរសក្តិ អគ្គានុរក្សពន្ធនាគារថ្នាក់លេខ ២ សមមូលជាមួយនឹងឋានន្តរសក្តិ :
- អនុសេនីយ៍ទោ នៃមន្ត្រីនគរបាលជាតិ
- នាយលេខាធិការរដ្ឋបាលថ្នាក់លេខ ៥ នៃមន្ត្រីរាជការស៊ីវិល

៣- ឋានន្តរសក្តិ អគ្គានុរក្សពន្ធនាគារថ្នាក់លេខ ៣ សមមូលជាមួយនឹងឋានន្តរសក្តិ :
- អនុសេនីយ៍ត្រី នៃមន្ត្រីនគរបាលជាតិ
- នាយលេខាធិការរដ្ឋបាល ថ្នាក់លេខ ៦ នៃមន្ត្រីរាជការស៊ីវិល

៤- ឋានន្តរសក្តិ អគ្គានុរក្សពន្ធនាគារថ្នាក់លេខ ៤ សមមូលជាមួយនឹងឋានន្តរសក្តិ :
- នាយចំណង់ នៃមន្ត្រីនគរបាលជាតិ
- លេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៨ ដល់ថ្នាក់លេខ ១ នៃមន្ត្រីរាជការស៊ីវិល

**ឃ. ឋានន្តរសក្តិ ថ្នាក់អនុរក្សពន្ធនាគារ**

១- ឋានន្តរសក្តិ អនុរក្សពន្ធនាគារថ្នាក់លេខ ១ សមមូលជាមួយនឹងឋានន្តរសក្តិ :
- ព្រិន្ទបាលឯក នៃមន្ត្រីនគរបាលជាតិ
- លេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ១០ ដល់ថ្នាក់លេខ ៩ នៃមន្ត្រីរាជការស៊ីវិល

២- ឋានន្តរសក្តិ អនុរក្សពន្ធនាគារថ្នាក់លេខ ២ សមមូលជាមួយនឹងឋានន្តរសក្តិ :
- ព្រិន្ទបាលទោ នៃមន្ត្រីនគរបាលជាតិ
- លេខាធិការរដ្ឋបាល ថ្នាក់លេខ ៧ ដល់ថ្នាក់លេខ ១ នៃមន្ត្រីរាជការស៊ីវិល
- ក្របខ័ណ្ឌប្រភេទ ឃ ថ្នាក់លេខ ៧ ដល់ថ្នាក់លេខ ១ នៃមន្ត្រីរាជការស៊ីវិល

៣- ឋានន្តរសក្តិ អនុរក្សពន្ធនាគារថ្នាក់លេខ ៣ សមមូលជាមួយនឹងឋានន្តរសក្តិ :
- ពលបាលឯក នៃមន្ត្រីនគរបាលជាតិ
- លេខាធិការរដ្ឋបាលថ្នាក់លេខ ១៤ ដល់ថ្នាក់លេខ ៨ នៃមន្ត្រីរាជការស៊ីវិល
- ក្របខ័ណ្ឌប្រភេទ ឃ ថ្នាក់លេខ ១៤ ដល់ថ្នាក់លេខ ៨ នៃមន្ត្រីរាជការស៊ីវិល

**មាត្រា៥.–**

ការធ្វើសមមូលឋានន្តរសក្តិនេះត្រូវគិតរយៈពេលបញ្ចូលពីអតីតភាពឋានន្តរសក្តិនៅអង្គភាពដើម។

## ជំពូកទី៣
## ការធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ
### ផ្នែកទី១
### ការធ្វើសមាហរណកម្មតាមមុខតំណែង

**មាត្រា៦.–**

មន្ត្រីរាជការដែលត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ គឺជាមន្ត្រីទាំងឡាយដែលកំពុងកាន់មុខតំណែងពិតប្រាកដនៅក្នុងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធនាគារ មណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត ដូចខាងក្រោម :

**ក. ឋានន្តរសក្តិ ថ្នាក់ឧត្តមអគ្គានុរក្សពន្ធនាគារ**

១- ឋានន្តរសក្តិ ឧត្តមអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ១
- អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ
- អគ្គនាយករង

២- ឋានន្តរសក្តិ ឧត្តមអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ២
- អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធនាគារ
- ប្រធាននាយកដ្ឋាន ចំណុះអគ្គនាយកដ្ឋានពន្ធនាគារ

៣- ឋានន្តរសក្តិ ឧត្តមអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ៣
- អនុប្រធាននាយកដ្ឋាន
- ប្រធានមណ្ឌលអប់រំកែប្រែ
- ប្រធានពន្ធនាគាររាជធានី ខេត្ត

**ខ. ឋានន្តរសក្តិ ថ្នាក់វរអគ្គានុរក្សពន្ធនាគារ**

១- ឋានន្តរសក្តិវរអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ១
- ប្រធានការិយាល័យនៅថ្នាក់កណ្តាល
- អនុប្រធានមណ្ឌលអប់រំកែប្រែ
- អនុប្រធានពន្ធនាគាររាជធានី ខេត្ត
- អនុប្រធានការិយាល័យថ្នាក់កណ្តាល ឬប្រធានការិយាល័យនៅមណ្ឌលអប់រំកែប្រែ ឬនៅពន្ធនាគាររាជធានី ខេត្ត ដែលមានអតីតភាពការងារក្នុងមុខតំណែងនេះ ចាប់ពី ០៨ឆ្នាំឡើង

២- ឋានន្តរសក្តិ វរអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ២
- អនុប្រធានការិយាល័យនៅថ្នាក់កណ្តាល
- ប្រធានការិយាល័យនៅមណ្ឌលអប់រំកែប្រែ
- ប្រធានការិយាល័យនៅពន្ធនាគាររាជធានី ខេត្ត
- ប្រធានផ្នែកថ្នាក់កណ្តាលឬអនុប្រធានការិយាល័យនៅមណ្ឌលអប់រំកែប្រែ ឬនៅពន្ធនាគាររាជធានី ខេត្ត ដែលមានអតីតភាពការងារក្នុងមុខតំណែងនេះ ចាប់ពី ០៨ ឆ្នាំឡើង

៣- ឋានន្តរសក្តិវរអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ៣
- ប្រធានផ្នែកនៅថ្នាក់កណ្តាល
- អនុប្រធានការិយាល័យនៅមណ្ឌលអប់រំកែប្រែ
- អនុប្រធានការិយាល័យនៅពន្ធនាគាររាជធានី ខេត្ត

**គ. ឋានន្តរសក្តិ ថ្នាក់អនុរក្សពន្ធនាគារ**

១- ឋានន្តរសក្តិ អគ្គានុរក្សពន្ធនាគារថ្នាក់លេខ ១
- អនុប្រធានផ្នែកនៅថ្នាក់កណ្តាល
- ប្រធានផ្នែកនៅមណ្ឌលអប់រំកែប្រែ
- ប្រធានផ្នែកនៅពន្ធនាគាររាជធានី ខេត្ត
- នាយត្រួតថ្នាក់កណ្តាល ឬអនុផ្នែកនៅមណ្ឌលអប់រំកែប្រែ ឬនៅពន្ធនាគាររាជធានី ខេត្ត ដែលមានអតីតភាពការងារក្នុងមុខតំណែងនេះចាប់ពី ០៨ឆ្នាំឡើង

២- ឋានន្តរសក្តិ អគ្គានុរក្សពន្ធនាគារថ្នាក់លេខ ២
- នាយត្រួតនៅថ្នាក់កណ្តាល
- អនុប្រធានផ្នែកនៅមណ្ឌលអប់រំកែប្រែ
- អនុប្រធានផ្នែកនៅពន្ធនាគាររាជធានី ខេត្ត
- នាយត្រួតរងថ្នាក់កណ្តាល ឬប្រធានក្រុមនៅមណ្ឌលអប់រំកែប្រែឬនៅពន្ធនាគាររាជ-ធានី ខេត្ត ដែលមានអតីតភាពការងារក្នុងមុខតំណែងនេះចាប់ពី០៨ឆ្នាំឡើង

៣- ឋានន្តរសក្តិ អគ្គានុរក្សពន្ធនាគារថ្នាក់លេខ ៣
- នាយត្រួតរងនៅថ្នាក់កណ្តាល
- ប្រធានក្រុមនៅមណ្ឌលអប់រំកែប្រែ
- ប្រធានក្រុមនៅពន្ធនាគាររាជធានី ខេត្ត

## ផ្នែកទី២
## ការធ្វើសមាហរណកម្មតាមប្រភេទក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់

**មាត្រា៧.-**

មន្ត្រីរាជការក្រសួងមហាផ្ទៃដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ត្រូវធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ដូចខាងក្រោម :

**ក. ឋានន្តរសក្តិ ថ្នាក់ឧត្តមអគ្គានុរក្សពន្ធនាគារ**

១- ឋានន្តរសក្តិ ឧត្តមអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ១
- ឧត្តមសេនីយ៍ឯក នៃមន្ត្រីនគរបាលជាតិ
- ឧត្តមមន្ត្រី នៃមន្ត្រីរាជការស៊ីវិល
- ឧត្តមសេនីយ៍ទោ ឬវរមន្ត្រីចាប់ពីថ្នាក់លេខ ៤ ដែលមានអតីតភាពការងារចាប់ពី២៥ ឆ្នាំឡើង

២- ឋានន្តរសក្តិ ឧត្តមអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ២
- ឧត្តមសេនីយ៍ទោ នៃមន្ត្រីនគរបាលជាតិ
- វរមន្ត្រី នៃមន្ត្រីរាជការស៊ីវិល
- ឧត្តមសេនីយ៍ត្រី ឬចាប់ពីអនុមន្ត្រីចាប់ពីថ្នាក់លេខ៥ ដែលមានអតីតភាពការងារចាប់ពី២០ ឆ្នាំឡើង

៣- ឋានន្តរសក្តិឧត្តមអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ៣
- ឧត្តមសេនីយ៍ត្រី នៃមន្ត្រីនគរបាលជាតិ
- អនុមន្ត្រី នៃមន្ត្រីរាជការស៊ីវិល
- វរសេនីយ៍ឯក ឬនាយក្រមការថ្នាក់លេខ ១ ដែលមានអតីតភាពការងារ ចាប់ពី២០ឆ្នាំឡើង

**ខ. ឋានន្តរសក្តិ ថ្នាក់វរអគ្គានុរក្សពន្ធនាគារ**

១- ឋានន្តរសក្តិ វរអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ១
- វរសេនីយ៍ឯក នៃមន្ត្រីនគរបាលជាតិ
- នាយក្រមការ នៃមន្ត្រីរាជការស៊ីវិល
- វរសេនីយ៍ទោ ឬក្រមការដើមខ្សែចាប់ពីថ្នាក់លេខ ៤ ដែលមានអតីតភាពការងារចាប់ពី២០ ឆ្នាំឡើង

២- ឋានន្តរសក្តិ វរអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ២
- វរសេនីយ៍ទោ នៃមន្ត្រីនគរបាលជាតិ
- ក្រមការដើមខ្សែ នៃមន្ត្រីរាជការស៊ីវិល
- វរសេនីយ៍ត្រី ឬក្រមការចាប់ពីថ្នាក់លេខ ៥ ដែលមានអតីតភាពការងារចាប់ពី២០ឆ្នាំឡើង

៣- ឋានន្តរសក្តិ វរអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ៣
- វរសេនីយ៍ត្រី នៃមន្ត្រីនគរបាលជាតិ
- ក្រមការ នៃមន្ត្រីរាជការស៊ីវិល
- នាយលេខាធិការថ្នាក់លេខ ១ ឬនាយអនុរក្ស ថ្នាក់លេខ ១
- អនុសេនីយ៍ឯក ដែលមានអតីតភាពការងារចាប់ពី ២០ឆ្នាំឡើង

**គ. ឋានន្តរសក្តិ ថ្នាក់អគ្គានុរក្សពន្ធនាគារ**

១- ឋានន្តរសក្តិ អគ្គានុរក្សពន្ធនាគារថ្នាក់លេខ ១
- អនុសេនីយ៍ឯក នៃមន្ត្រីនគរបាលជាតិ
- នាយលេខាធិការរដ្ឋបាល ថ្នាក់លេខ ៤ ដល់ថ្នាក់លេខ ២ នៃមន្ត្រីរាជការស៊ីវិល
- នាយអនុរក្សពន្ធនាគារ ថ្នាក់លេខ ៤ ដល់ថ្នាក់លេខ ២

២- ឋានន្តរសក្តិ អគ្គានុរក្សពន្ធនាគារថ្នាក់លេខ ២
- អនុសេនីយ៍ទោ នៃមន្ត្រីនគរបាលជាតិ
- នាយលេខាធិការរដ្ឋបាល ថ្នាក់លេខ ៥ នៃមន្ត្រីរាជការស៊ីវិល
- នាយអនុរក្សពន្ធនាគារ ថ្នាក់លេខ ៥

៣- ឋានន្តរសក្តិអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ៣
- អនុសេនីយ៍ត្រី នៃមន្ត្រីនគរបាលជាតិ
- នាយលេខាធិការរដ្ឋបាល ថ្នាក់លេខ ៦ នៃមន្ត្រីរាជការស៊ីវិល
- នាយអនុរក្សពន្ធនាគារ ថ្នាក់លេខ ៦

៤-  ឋានន្តរសក្តិអគ្គានុរក្សពន្ធនាគារថ្នាក់លេខ ៤

- នាយចំណង់ នៃមន្ត្រីនគរបាលជាតិ

- លេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៨ ដល់ថ្នាក់លេខ ១ នៃមន្ត្រីរាជការស៊ីវិល

- អនុរក្សពន្ធនាគារដើមខ្សែ ថ្នាក់លេខ ៨ ដល់ថ្នាក់លេខ ១

**ឃ. ឋានន្តរសក្តិ ថ្នាក់អនុរក្សពន្ធនាគារ**

១- ឋានន្តរសក្តិ អនុរក្សពន្ធនាគារថ្នាក់លេខ ១

- ព្រិន្ទបាលឯក នៃមន្ត្រីនគរបាលជាតិ

- លេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ១០ ដល់ថ្នាក់លេខ ៩ នៃមន្ត្រីរាជការស៊ីវិល

- អនុរក្សពន្ធនាគារដើមខ្សែ ថ្នាក់លេខ ១០ ដល់ថ្នាក់លេខ៩

២-  ឋានន្តរសក្តិ អនុរក្សពន្ធនាគារថ្នាក់លេខ ២

- ព្រិន្ទបាលទោ នៃមន្ត្រីនគរបាលជាតិ

- លេខាធិការរដ្ឋបាល ថ្នាក់លេខ ៧ ដល់ថ្នាក់លេខ ១ នៃមន្ត្រីរាជការស៊ីវិល

- អនុរក្សពន្ធនាគារ ថ្នាក់លេខ ៧ ដល់ថ្នាក់លេខ ១

- ក្របខ័ណ្ឌប្រភេទ ឃ ថ្នាក់លេខ ១៤ ដល់ថ្នាក់លេខ ១ នៃមន្ត្រីរាជការស៊ីវិល

៣- ឋានន្តរសក្តិ អនុរក្សពន្ធនាគារថ្នាក់លេខ ៣

- ពលបាលឯក នៃមន្ត្រីនគរបាលជាតិ

- លេខាធិការរដ្ឋបាល ថ្នាក់លេខ ១៤ ដល់ថ្នាក់លេខ ៨ នៃមន្ត្រីរាជការស៊ីវិល

- អនុរក្សពន្ធនាគារ ថ្នាក់លេខ ១៤ ដល់ថ្នាក់លេខ ៨។

**មាត្រា៨.-**

មន្ត្រីរាជការដែលត្រូវធ្វើសមាហរណកម្មចូលទៅក្នុងឋានន្តរសក្តិថ្នាក់  អគ្គានុរក្សពន្ធនាគារឬឋានន្តរសក្តិអនុរក្សពន្ធនាគារ ប្រសិនបើសាមីខ្លួនមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ ត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងឋានន្តរសក្តិវរអគ្គានុរក្សថ្នាក់លេខ ៣ ជាការធ្វើសមាហរណកម្មតាមគោលការណ៍សញ្ញាបត្រ។

ក្នុងដំណើរការសមាហរណកម្មតាមស្មារតីអនុក្រឹត្យនេះ ត្រូវធានាឱ្យបាននូវគោលការណ៍សមធម៌ និងអត្ថប្រយោជន៍របស់មន្ត្រីរាជការ។

**មាត្រា៩.-**

ក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីសម្រេចបង្កើតគណៈកម្មការមួយ ដើម្បីធ្វើសមាហរណកម្មផ្ទេរបញ្ចូលមន្ត្រីរាជការដែលស្ថិតក្នុងក្របខ័ណ្ឌអនុរក្សពន្ធនាគារ ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិទៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមហត្ថលេខា។
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**<u>កន្លែងទទួល</u>** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ